**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តត្បូងឃ្មុំ**
លេខ : ៤២៦/សរ.ណ.គឃ
២០

ថ្ងៃពុធ ៦កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
ត្បូងឃ្មុំ ថ្ងៃទី២៣ខែ កញ្ញា ឆ្នាំ២០២០

## សេចក្តីជូនដំណឹង
## ស្តីពី
## ការរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០២១

រដ្ឋបាលខេត្តត្បូងឃ្មុំ នឹងរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០២១ សម្រាប់ដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០២១។ អ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ មានសិទ្ធិដាក់សំណើដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់ទាំងអស់ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

អ្នកទទួលការត្រូវបានបែងចែកជា ០៣ ប្រភេទ ៖

- ប្រភេទទី១ ៖ អ្នកទទួលការសំណង់ទូទៅ (សំណង់អគារ និងការងារបេតុង ...។ល។)
- ប្រភេទទី២ ៖ អ្នកទទួលការការងារដី(ប្រឡាយ ទំនប់ ទ្វារទឹកខ្នាតតូច ផ្លូវដីស ផ្លូវក្រួសក្រហម លូមូល...។ល។)
- ប្រភេទទី៣ ៖ អ្នកទទួលការឯកទេស(អ្នកទទួលការដែលមានឧបករណ៍ និងជំនាញបច្ចេកទេសសម្រាប់ការងារពិសេស ឧទាហរណ៍ អណ្តូងស្នប់ ...។ល។)

អ្នកទទួលការត្រូវមានបុគ្គលិកបច្ចេកទេស និងសម្ភារបរិក្ខារគ្រប់គ្រាន់ ដូចមានបរិយាយនៅក្នុងពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ ដើម្បីអនុវត្តការងារទៅតាមប្រភេទដែលបានស្នើសុំ ហើយត្រូវមានបទពិសោធន៍អនុវត្តគម្រោងយ៉ាងតិច ០២ ទាក់ទងទៅនឹងប្រភេទនីមួយៗដែលបានស្នើសុំ ក្នុងអំឡុងពេល៥ឆ្នាំចុងក្រោយ។ គណៈកម្មការបុរេលក្ខណៈសម្បត្តិនឹងចុះពិនិត្យដល់ទីតាំងក្រុមហ៊ុនរបស់អ្នកទទួលការ និងវាយតម្លៃសមត្ថភាពបច្ចេកទេសដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដូចមានបរិយាយនៅក្នុងពាក្យសុំចុះបញ្ជី ព្រមទាំងពិនិត្យមើលគុណភាពការងារ ភាពស្មោះត្រង់ ការអនុវត្តការងារទាន់ពេលវេលា និងកិច្ចសហប្រតិបត្តិការរបស់អ្នកទទួលការជាមួយម្ចាស់គម្រោង ដោយផ្អែកលើកំណត់ត្រាកន្លងមក។ លទ្ធផលនៃការវាយតម្លៃនេះ គណៈកម្មការបុរេលក្ខណៈសម្បត្តិ នឹងដាក់ជូនអភិបាលខេត្តដើម្បីពិនិត្យ និងសម្រេច។

អ្នកទទួលការទាំងឡាយណាដែលត្រូវបានរកឃើញថា មានការពាក់ព័ន្ធនឹងការឃុបឃិត ការក្លែងបន្លំ និងអំពើពុករលួយ ហើយចាប់ពីពេលដែលត្រូវបានដកសិទ្ធិជាផ្លូវការ អ្នកទទួលការនោះ នឹងមិនត្រូវបានពិចារណាក្នុងការបញ្ចូលឈ្មោះទៅក្នុងបញ្ជីឈ្មោះអ្នកទទួលការឡើយ។

អាស្រ័យហេតុនេះ បើអ្នកទទួលការមានបំណងចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ សូមប្រញាប់មកដាក់ពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការនៅទីចាត់ការផែនការ និងវិនិយោគខេត្ត ចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់ថ្ងៃទី២៥ ខែ តុលា ឆ្នាំ២០២០ វេលាម៉ោង ១៧:០០ នាទី។ ចំពោះអ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីឆ្នាំកន្លងមក ក៏ត្រូវដាក់ពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការជាថ្មីឡើងវិញដែរ។ អ្នកទទួលការអាចមកយកពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ នៅទីចាត់ការផែនការ និងវិនិយោគខេត្ត ដោយឥតបង់ថ្លៃ តាមអាសយដ្ឋាន ភូមិនិគមលើ ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។

**អភិបាលខេត្ត**

**ជាម ច័ន្ទសោភ័ណ**